# កំណត់សម្គាល់ត្រូវយកចិត្តទុកដាក់សម្រាប់សិស្សបន្ទាប់ពីការចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយ និងសេចក្តីជូនដំណឹងអំពីការបន្ថែមចាក់វ៉ាក់សាំង

ការរំពឹងអំពីការចាក់វ៉ាក់សាំងសម្រាប់ឪពុកម្តាយ ជូនដោយសាលា______

ខេត្ត(ក្រុង)__________

កូនរបស់លោកអ្នកឈ្មោះ________ក្នុងថ្នាក់___ឆ្នាំ_______អត្តលេខ_______ នៅថ្ងៃទី___ ខែ__ ឆ្នាំ______

□ បានចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយរួចហើយ □ មិនទាន់ចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយទេ(មូលហេតុដែលមិនបានចាក់វ៉ាក់សាំង៖

_____________ហើយសូមយកសេចក្តីជូនដំណឹងនេះមកមណ្ឌលសុខភាព/មណ្ឌលពេទ្យ__________ដើម្បីចាក់វ៉ាក់សាំងមុនថ្ងៃទី ___ ខែ ___ ឆ្នាំ២០២៣(មុននឹងទៅចាក់វ៉ាក់សាំង ស្នើលោកអ្នកទាក់ទងជាមួយមន្ទីរពេទ្យជាប់កិច្ចសន្យាបានកំណត់ ដើម្បីបញ្ជាក់ថានៅមានវ៉ាក់សាំងឬទេ ទើបទៅចាក់វ៉ាក់សាំង)។

ហត្ថលេខានិងត្រារបស់គ្រូពេទ្យ៖ __________

ចំណាំ៖ កាលណាលោកអ្នកយកលិខិតនេះទៅមន្ទីរពេទ្យជាប់កិច្ចសន្យាបានកំណត់ដើម្បីចាក់វ៉ាក់សាំង លោកអ្នកត្រូវបង់ថ្លៃព្យាបាលដែលពាក់ព័ន្ធដោយខ្លួនឯង ស្របតាមកំណត់របស់មន្ទីរពេទ្យ។

【កំណត់សម្គាល់ក្រោយពេលចាក់វ៉ាក់សាំង】

មួយ.វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយគឺជាវ៉ាក់សាំងអសកម្មដែលមានសុវត្ថិភាពខ្លាំង បន្ទាប់ពីចាក់វ៉ាក់សាំង នៅកន្លែងចាក់វ៉ាក់សាំងមានលទ្ធភាពអាចមានការឈឺចាប់ ក្រហមនិងហើម មានមនុស្សតិចតួចនឹងមានប្រតិកម្មស្រាលក្នុងទូទាំងខ្លួន ដូចជា គ្រុនក្តៅ ឈឺក្បាល ឈឺសាច់ដុំ ចង្អោរ រមាស់ស្បែក កញ្ជ្រឹលឬកន្ទួលក្រហមជាដើម ប៉ុន្តែតាមធម្មតានឹងជាសះស្បើយក្នុងរយៈពេលមួយទៅពីរថ្ងៃបន្ទាប់ពីការចាក់វ៉ាក់សាំង ហើយផលប៉ះពាល់ធ្ងន់ធ្ងរគឺកម្រមានណាស់។

ពីរ.មានមនុស្សចំនួនប្រហែល1-2%អាចមានប្រតិកម្មក្តៅខ្លួនក្នុងរយៈពេល48 ម៉ោងបន្ទាប់ពីចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយ ត្រូវតែប្រាប់ដល់គ្រូពេទ្យថាខ្លួនធ្លាប់ចាក់វ៉ាក់សាំងផ្តាសាយពីមុន ដើម្បីធ្វើជាឯកសារយោងសម្រាប់គ្រូពេទ្យ វិនិច្ឆ័យរោគ។ ប្រសិនបើបន្ទាប់ពីការចាក់វ៉ាក់សាំង48ម៉ោងនៅតែបន្តក្តៅខ្លួន គួរតែពិចារណាថា មានការឆ្លងផ្សេងទៀត ឬមូលហេតុនៃគ្រុនក្តៅ។

បី.បន្ទាប់ពីចាក់វ៉ាក់សាំង ប្រសិនបើមានគ្រុនក្តៅជាប់លាប់ ស្មារតីឬអាកប្បកិរិយាមានការប្រែប្រួល ពិបាកដកដង្ហើម បេះដូងលោតញាប់ និងរោគសញ្ញាមិនស្រួលផ្សេងទៀត គួរតែទៅមន្ទីរពេទ្យព្យាបាលឱ្យបានឆាប់តាមលទ្ធភាព ហើយជូនដំណឹងទៅគ្រូ/បុគ្គលិកគិលានុបដ្ឋាយិការបស់សាលារៀន ឬហៅលេខទូរសព្ទប្រឹក្សាដូចខាងក្រោម នឹងមានបុគ្គលិកពិសេសផ្តល់សេវាកម្មសម្រាប់លោកអ្នក។

បួន. ការដួលសន្លប់ដោយការចាក់វ៉ាក់សាំង តាមធម្មតាបណ្តាលមកពីសម្ពាធផ្លូវចិត្ត និងក្តីភ័យខ្លាចចំពោះការចាក់វ៉ាក់សាំង ដែលប្រែក្លាយទៅជារោគសញ្ញារាងកាយ ដូចជាវិលមុខនិងចង្អោរជាដើម ភាគច្រើនកើតឡើងនៅពេលក្មេងជំទង់មួយក្រុមទទួលការចាក់វ៉ាក់សាំង។ ក្នុងអំឡុងពេលចាក់វ៉ាក់សាំងទ្រង់ទ្រាយធំ ជួនកាលនឹងកើតឡើងការដួលសន្លប់ជាក្រុម មេះត្រូវបានគេហៅថាជាជំងឺផ្លូវចិត្តជាសមូហភាព។ ប្រតិកម្មដួលសន្លប់ដោយសារចាក់វ៉ាក់សាំងគ្មានពាក់ព័ន្ធនឹងសុវត្ថិភាពនៃថ្នាំវ៉ាក់សាំងនោះទេ ហើយមិនដែលបង្កផលវិបាកដល់សុខភាពសោះ។ បន្ទាប់ពីត្រឡប់មកផ្ទះវិញ ប្រសិនបើសិស្សបន្តដួលសន្លប់ គួរតែបញ្ជូនទៅគ្រូពេទ្យ ដើម្បីវិនិច្ឆ័យនិងព្យាបាល។

ប្រាំ.ទោះបីជាការចាក់វ៉ាក់សាំងអាចកាត់បន្ថយឱកាសនៃការឆ្លងជំងឺគ្រុនផ្តាសាយក៏ដោយ

ក៏នៅតែមានលទ្ធភាពឆ្លងមេរោគផ្លូវដង្ហើមដែលបណ្ដាលមកពីមេរោគដែលមិនមែនជាជំងឺគ្រុនផ្ដាសាយផ្សេងទៀត ដូច្នេះ សូមយកចិត្តទុកដាក់លើអនាម័យផ្ទាល់ខ្លួន និងចាត់វិធានការបង្ការផ្សេងៗដើម្បីរក្សាសុខភាពខ្លួន។

ប្រាំមួយ.ចំពោះអ្នកដែលប្រើប្រាស់ថ្នាំប្រឆាំងនឹងប្លាកែត ឬថ្នាំប្រឆាំងនឹងកំណកឈាម ឬមានមុខងារកកឈាមខុសប្រក្រតី ត្រូវដាក់សំពាធទៅកន្លែងចាក់វ៉ាក់សាំងយ៉ាងហោចណាស់2នាទីបន្ទាប់ពីចាក់វ៉ាក់សាំង ហើយសង្កេតមើលថាតើនៅតែមានករណីហូរឈាម ឬដុំពកបង្កដោយឈាមឬទេ។

ប្រាំពីរ.ប្រសិនបើកូនរបស់លោកអ្នកជាសិស្សទាបជាងថ្នាក់ទី2ក្នុងបឋមសិក្សដែលបានចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្ដាសាយជាលើកដំបូងតាំងពីកំណើត បើសិនលោកអ្នកយល់ឃើញថាត្រូវការ បន្ទាប់ពីការចាក់វ៉ាក់សាំងលើកដំបូងយ៉ាងហោចណាស់៤អាទិត្យ លោកអ្នកអាចទៅមន្ទីរពេទ្យទទួលការចាក់វ៉ាក់សាំងលើកទី 2 ដោយបង់ថ្លៃផ្ទាល់ខ្លួន។

មន្ទីរសុខភាព____________________សូមគោរពជូន

មន្ទីរសុខភាព________________លេខទូរស័ព្ទពិគ្រោះពិសេស___________________

នាយកដ្ឋានគ្រប់គ្រងជំងឺ លេខទូរស័ព្ទពិសេសសម្រាប់រាយការណ៍និងពិគ្រោះជំងឺ ៖ 1922

សាលារៀន__________________លេខទូរស័ព្ទពិគ្រោះពិសេស_________________